**សេចក្តីប្រកាសនៃគណៈកម្មការនាយកផ្នែកសិក្សាធិការអំពីការបណ្តេញចោលភ្នាក់ងារប៉ូលីសសាលារៀនម្នាក់ពីការងារ**

ជម្រាបជូនប្រជារាស្ត្រនៃក្រសួងអប់រំ ឪស្ត្រីគ ឡុងប៊ីច,

ក្នុងនាមជាសមាជិកនៃគណៈកម្មការសាលារៀនរបស់លោកអ្នក ដែលបានទទួលកាន់តំណែងតាមរយៈបោះឆ្នោត គឺយើងបានធ្វើការសម្រេចភ្លាមក្នុងសប្តាហ៍នេះអំពីការបណ្តេញចោលភ្នាក់ងារប៉ូលីសសាលារៀនម្នាក់ពីការងារ ដែលបានជាប់ទាក់ទងព្រឹត្តការណ៍បាញ់កាំភ្លើងក្រៅបរិវេណនៃសាលារៀននៅ ថ្ងៃចន្ទ ទី27 ខែកញ្ញា ។

យើងទាំងអស់គ្នាមានសេចក្តីក្រៀមក្រំចិត្តយ៉ាងខ្លាំងមកលើព្រឹត្តិការណ៍នេះ ហើយយើងដឹងថា មានប្រជារាស្ត្រជាច្រើននៅក្នុងសហគមន៍សាលារៀនរបស់យើងកំពុងតែកាន់ទុក្ខសោករួមគ្នា ។ សូមផ្ញើសេចក្តីអាណិតរបស់យើងទៅកាន់ម្នាក់ៗទាំងឡាយណា ដែលបានទទួលការប៉ះទង្គិចដោយព្រឹត្តិការណ៍ខ្លោចផ្សានេះ ជាពិសេស ទៅកាន់ក្រុមគ្រួសារ មិត្តភ័ក្ត និង សមាជិកជាទីស្រឡាញ់នៃអ្នករងគ្រោះ គឺ Manuela Rodriguez ។

យើងបានធ្វើការបោះឆ្នោតផ្តល់សម្លេងស្របគ្នា ដើម្បីបណ្តេញចោលភ្នាក់ងារប៉ូលីសម្នាក់នេះពីការងារ បន្ទាប់ពីមានការស៊ើបអង្កេតផ្ទៃក្នុងយ៉ាងច្បាស់លាស់ ដែលបញ្ជាក់ថា បុគ្គលិកម្នាក់នេះបានប្រព្រឹត្តល្មើសច្បាប់នៃក្រសួងអប់រំ ឪស្ត្រីគ និង មិនបានបំពេញស្របតាមអ្វីជាសេចក្តីសង្ឃឹមរបស់យើង ។ ច្បាប់ទាក់ទងការប្រើ "កម្លាំងអាវុធ" ដែលត្រូវប្រើសម្រាប់ភ្នាក់ងារប៉ូលីសសាលារៀនរបស់យើងបានបញ្ជាក់មកថា ភ្នាក់ងារប៉ូលីស 1) មិនត្រូវបាញ់កាំភ្លើងទៅកាន់បុគ្គលទេ នៅពេលណាគេភៀសខ្លួនចេញ 2) មិនត្រូវបាញ់កាំភ្លើងទៅកាន់រថយន្តកំពុងតែកម្រើក 3) មិនត្រូវបាញ់កាំភ្លើងទៅកាន់កញ្ចក់បង្អួចរថយន្ត លុះត្រាតែមានមូលហេតុបង្ហាញយ៉ាងច្បាស់លាស់ថា ការប្រើកាំភ្លើង គឺជាមធ្យោបាយចុងក្រោយបង្អស់សម្រាប់ការពារខ្លួន ។ យោងតាមការសើរើមើលយ៉ាងដិតដល់របស់យើង គឺយើងបានរកឃើញថា ច្បាប់ផ្ទៃក្នុងត្រូវបានទទួលការប្រព្រឹត្តល្មើស ។

ការស៊ើបអង្កេតខាងបទឧក្រិដ្ឋកំពុងតែធ្វើជាបន្ត ហើយស្ថិតនៅក្រោមការគ្រប់គ្រងដោយក្រសួងប៉ូលីស ឡុងប៊ីច និង ការិយាល័យនៃមេធាវីប្រចាំ ឡូស អ៊ែនជេឡេស ខោនធី ។ យើងអាចនិយាយបានតែអំពីច្បាប់របស់យើងផ្ទាល់ប៉ុណ្ណោះ ហើយត្រូវតែបញ្ជូនសំនួរផ្សេងៗអំពីបទឧក្រិដ្ឋទៅកាន់ក្រសួងទាំង ពីរ ។ សូមលោកអ្នកទទួលភាពកក់ក្តៅ នៅពេលយើងបន្តសហការណ៍យ៉ាងពេញកម្រិតជាមួយការស៊ើបអង្កេតស្របច្បាប់ ។

យើងក៏បានទទួលដំណឹងដែរមកពីសមាជិកភាគច្រើនក្នុងសហគមន៍ ដែលចង់ដឹងថា តើសុវត្ថិភាពនៅតាមសាលារៀននឹងមានភាពដូចម្តេចដែរនៅពេលយើងបន្តកិច្ចការទៅមុខ ។ សហគមន៍របស់យើងបានលើកបង្ហាញយ៉ាងខ្លាំងៗអំពីបញ្ហានេះ ហើយយើងកំពុងតែស្តាប់ ។ យើងមានការប្តេជ្ញាចិត្ត ដើម្បីសាងសង់ក្រសួងអប់រំ ឪស្ត្រីគ ឱ្យមានភាពកាន់តែមាំមួន ស្របដោយសុវត្ថិភាពកាន់តែប្រសើរ ។ គម្រោងផ្តើមធ្វើភ្លាមសម្រាប់យើង គឺបើកឱកាសទទួលស្តាប់ និង ធ្វើការពិគ្រោះទៅមកអំពីសុវត្ថិភាព និង សុខុមាលភាព មិនត្រឹមតែសម្រាប់សិស្សនោះទេ គឺថែមទាំងទៅកាន់ក្រុមគ្រួសារ និង សមាជិកក្នុងសហគមន៍ទៀតផង ។ យើងរង់ចាំបំពេញកិច្ចការយ៉ាងដិតដល់ជាមួយក្រសួងជាដៃគូផ្សេងៗក្នុងសហគមន៍របស់យើង និង ស្វែងរកមធ្យោបាយ ដែលអាចជួយបានកាន់តែល្អឡើងទៅកាន់សិស្សនៅតាមសាលារៀនក្នុងគ្រានេះ និង ធ្វើការសើរើមើល និង ពង្រឹងមធ្យោបាយចាត់ចែងរបស់យើង រួមទាំងការប្រើអំពីយុត្តិធម៌ឡើងវិញ ដែលជាប់ទាក់ទងនឹងផ្នែកសុវត្ថិភាព និង សុខុមាលភាពនៃសិស្ស ។ យើងនឹងបន្តការបើកទំនាក់ទំនងជាមួយសហគមន៍សាលារៀនរបស់យើង ដោយធ្វើការរួមគ្នាសម្រាប់ចាត់ចែងកិច្ចការ ដែលផ្តល់ជាសុវត្ថិភាព និង ការទទួលស្វាគមន៍នៅក្នុងបរិវេណនៃសាលារៀន ដែលសិស្សរបស់យើង*ទាំងអស់* អាចទទួលយកការរៀន និង ភាពលូតលាស់ល្អបាន ។

យើងសង្ឃឹមថា ដំណឹងបន្ថែមអំពីព្រឹត្តិការណ៍នេះនឹងមានលេចឡើង នៅពេលការស៊ើបអង្កេតស្របច្បាប់បានធ្វើបញ្ចប់ផុតទៅ ។ ក្នុងរយៈពេលឥឡូវ គឺយើងដឹងថា យើងបានបាត់បង់ស្ត្រីក្មេងម្នាក់យ៉ាងខ្លោចផ្សា ហើយត្រូវទុកពេលសម្រាប់ម្នាក់ៗ ដែលបានទទួលការប៉ះទង្គិចដោយព្រឹត្តិការណ៍នេះធ្វើការកាន់ទុក្ខសោក និង បន្ធូរទុក្ខសោកស្របតាមមធ្យោបាយពិសេសអ្វី ដែលពួកគេអាចធ្វើទៅបាន ។ នេះក៏ជាគ្រាមួយផងដែរសម្រាប់ក្រសួងអប់រំ ឪស្ត្រីគ របស់យើងប្រព្រឹត្តតាមគោលតម្លៃដ៏ខ្ពង់ខ្ពស់របស់យើងធ្លាប់មានជាយូរមកហើយ ដែលប៉ះពាល់មកលើរបៀបបុគ្គលិករបស់យើងធ្វើទំនាក់ទំនងទៅកាន់សិស្ស ក្រុមគ្រួសារ និង សមាជិកក្នុងសហគមន៍ ។ ទំនាក់ទំនងទាំងអស់នោះឯង គឺគួរធ្វើស្របដោយសេចក្តីគោរពដាក់គ្នា បង្ហាញការគាំទ្រ និង ការយកចិត្តទុកដាក់ជាមួយគ្នាទៅវិញទៅមក ។ គណៈកម្មការរបស់យើង និង ក្រុមរួមរបស់យើងទាំងអស់នៅតែកាន់ការប្តេជ្ញាចិត្តយ៉ាងជ្រៅបំផុតមកលើគោលតម្លៃដ៏ខ្ពង់ខ្ពស់ទាំងអស់នោះ ។

យើងសូមធ្វើការជម្រុញដល់លោកអ្នកឱ្យនៅតែបង្កើនទំនាក់ទំនង និង បន្តការចូលរួមចំណែក ដើម្បីឱ្យយើងទាំងអស់គ្នាអាចសាងសង់ក្រសួងអប់រំ ឪស្ត្រីគ ឡុងប៊ីច បានកាន់តែប្រសើរសម្រាប់យើងទាំងអស់គ្នា ។

ដោយសេចក្តីគោរព,

Juan Benitez, Ph. D. ប្រធាន

Megan Kerr, អនុប្រធាន

Diana Craighead, សមាជិក

Erik Miller, សមាជិក

Douglas Otto, សមាជិក